# II- ការងារបណ្តាក្រសួង

## ទីស្តីការរដ្ឋមន្ត្រីក្រសួងសុខាភិបាល

*រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ១៩៩៤*

## ប្រកាស

### ប្រកាសលេខ ០១ ស.ន.ក្រ

### ស្តីពីការគ្រប់គ្រង និងសុវត្ថិភាពឈាម

រដ្ឋមន្ត្រីក្រសួងសុខាភិបាល

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល
- យោងទៅតាមសេចក្តីត្រូវការចាំបាច់របស់ក្រសួង

### សំរេច

**ប្រការ ១ :** ឈាមគឺជាថាមពលនៃជីវិត និងជាឱសថសំរាប់សង្គ្រោះជីវិតសាធារណៈជន ដែលមានរបួស និងជំងឺ ។

**ប្រការ ២ :** ដើម្បីកាត់ផ្តាច់ភាពចំលងរោគ តាមការបញ្ចូលឈាម និងផលិតផលធ្វើពីឈាម ដល់អ្នករបួស និងជំងឺ ឈាមទាំងឡាយដែលបានមកពីសប្បុរសជន ឬ អ្នកធ្វើអំណោយ ចាំបាច់ត្រូវធ្វើការ ត្រួតពិនិត្យវិភាគអោយបានល្អិតល្អន់ ។ អ្នកធ្វើអំណោយឈាមត្រូវទទួលការពិនិត្យសុខភាពពីគ្រូពេទ្យជាមុន ។

**ប្រការ ៣ :** មជ្ឈមណ្ឌលជាតិផ្តល់ឈាម គឺជាបង្អែកមួយរបស់មជ្ឈមណ្ឌលផ្តល់ឈាម ក្រុង-ខេត្ត ក្រោមឱវាទ មានភារកិច្ច រិះរកឈាម ធ្វើការវិភាគឈាម និងចែកចាយឈាមដល់មន្ទីរពេទ្យព្យាបាល ក្នុងព្រះរាជាណាចក្រកម្ពុជា ។

**ប្រការ ៤ :** រាល់ការប្រមូលឈាម ឬទទួលអំណោយឈាមពីសប្បុរសជន ឬអ្នកធ្វើអំណោយ អាចធ្វើបានតែក្នុងបរិវេណនៃមជ្ឈមណ្ឌលផ្តល់ឈាម និងក្រុមចល័តរបស់មជ្ឈមណ្ឌល ដែលមាននៅតាម ក្រុង-ខេត្ត ប៉ុណ្ណោះ ។

ក្នុងករណីនេះ មន្ទីរព្យាបាលទាំងអស់ បើមានការជាបន្ទាន់ក្នុងការបញ្ចូលឈាមដើម្បីជួយសង្គ្រោះអ្នកជម្ងឺរបួស ចាំបាច់ត្រូវបញ្ជូនអ្នកផ្តល់ឈាមជំនួស "ប្រសិនបើមាន" ទៅកាន់មជ្ឈមណ្ឌលផ្តល់ឈាមក្រុង-ខេត្ត ដើម្បីពិនិត្យសុខភាព ប្លុមឈាម និងធ្វើការវិភាគជាមុន ទើបអាចយកទៅប្រើបាន ។

**ប្រការ ៥ :** មន្ទីរព្យាបាលឯកជនទាំងអស់ អាចធ្វើការទំនាក់ទំនងសុំបើកឈាមពីមជ្ឈមណ្ឌល ជាតិផ្តល់ឈាមនៅភ្នំពេញ និងមជ្ឈមណ្ឌលផ្តល់ឈាមក្រុង-ខេត្ត បានគ្រប់ពេលដូចមន្ទីរពេទ្យរដ្ឋដែរ តែត្រូវបញ្ជូនអ្នកអោយឈាមជំនួស ទៅមជ្ឈមណ្ឌលផ្តល់ឈាម ក្រុង-ខេត្តវិញ នៅពេលទៅបើកឈាម និងចាំបាច់ត្រូវបង់ថ្លៃពិនិត្យវិភាគរកគុណភាពឈាម និងថ្លៃសេវាកម្មផ្សេងៗ ។ កំរៃដែលបានមកពីការពិនិត្យវិភាគឈាម ប្លុមឈាម និងសេវាកម្មផ្សេងៗ ត្រូវបង់ចូលក្នុងថវិកាជាតិទាំងអស់ ដោយផ្អែកលើបង្កាន់ដៃដែលមានគល់បញ្ជីច្បាស់លាស់ ។ មន្ទីរព្យាបាលឯកជនមិនត្រូវកេង ប្រវ័ញ្ច ថ្លៃពិនិត្យវិភាគនេះ ពីអ្នកជំងឺដើម្បីប្រយោជន៍ផ្ទាល់ខ្លួនឡើយ ។

**ប្រការ ៦ :** មជ្ឈមណ្ឌលផ្តល់ឈាមទាំងអស់ ត្រូវចាត់តាំងមន្ត្រីរាជការ ទទួលបន្ទុកពិនិត្យសុខភាព ប្លុមឈាម វិភាគឈាម និងចែកចាយឈាមជាប្រចាំគ្រប់ពេលម៉ោងទោះជាថ្ងៃត្រូវឈប់សំរាកក៏ដោយ តែត្រូវបានអនុញ្ញាតអោយឈប់សំរាកសងវិញនៅថ្ងៃបន្ទាប់ ។

**ប្រការ ៧ :** ឈាមដែលមន្ទីរព្យាបាលទាំងអស់បានទទួលពីមជ្ឈមណ្ឌលផ្តល់ឈាម ឬពីសប្បុរសជន គឺធ្វើឡើងដោយឥតគិតតំលៃឡើយ ហើយការផ្តល់ឈាមដល់ជនរងគ្រោះវិញ ក៏ពុំគិតថ្លៃដែរ ។

**ប្រការ ៨ :** ជនណាដែលបានប្រព្រឹត្តផ្ទុយនិងប្រការ ៤, ៥, និង ៧ នៃប្រកាសនេះ ឬ ប្រើប្រាស់មធ្យោបាយផ្សេងៗ និងល្បិចកលដើម្បីផលប្រយោជន៍ ផ្ទាល់ខ្លួន ត្រូវផ្តន្ទាទោសតាមច្បាប់ ។

**ប្រការ ៩ :** ប្រកាសនេះ មានអនុភាពតតិយុត្តិ ចាប់តាំងពីថ្ងៃដែលបានចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រីក្រសួងសុខាភិបាល

ហត្ថលេខា និង ត្រា

**វេជ្ជ. ឈា.ថាំង**

***